YUNNAN DAILY PRESS GROUP
No.180

ប្រទេសចិន-ខេត្តយូនណាន

ព្រឹត្តិប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7917 ថ្ងៃសុក្រ ទី26 ខែមេសា ឆ្នាំ2019

រឿងរ៉ាវអំពីឯកឧត្តមស៊ី ជីនភីង និងជនជាតិទួឡុង

ឃប់ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៥ ឯកឧត្តម ស៊ី ជីនភីងទទួលជួបតំណាងជនជាតិទួឡុងនៅក្រុង គុនមីង

នៅឆ្នាំ ២០១៨ ភូមិរដ្ឋបាលទាំង ៦ នៃឃុំទន្លេទួឡុង ស្រុកស្វយ័តជនជាតិទួឡុង និងជនជាតិន្ទ កុងសាន ខេត្តយូនណាន បានទទួលការជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រទាំងស្រុង ។ ប្រជាជនជនជាតិទួឡុង បានជ្រៀសផុតពីភាពក្រីក្រគ្រប់ៗគ្នា ។ ពួកគេបានសុំឱ្យគណៈរដ្ឋបាលភូមិជួយសរសេរសំបុត្រជូនឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតីចិន ដើម្បីរាយការណ៍ពីដំណឹងល្អអំពីការកាត់បន្ថយភាពក្រីក្រទាំងស្រុងរបស់ជនជាតិទួឡុង ។

នៅថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៩ ឯកឧត្តម ស៊ី ជីនភីង បាន សរសេរសំបុត្រឆ្លើយតបអ្នកស្រុក ជនជាតិទួឡុង ដើម្បីសម្តែងនូវអំណរសាទរចំពោះជនជាតិទួឡុងដែលបានសម្រេចនូវការកាត់បន្ថយភាពក្រីក្រ ទាំងស្រុង ។

ឯកឧត្តម បានសរសេរក្នុងសំបុត្រនេះថា ធ្វើឱ្យប្រជាជនគ្រប់ជនជាតិទទួលបានការរស់នៅយ៉ាងល្អប្រសើរ គឺជាក្តីសង្ឃឹមរបស់ខ្ញុំជាប់រហូតមក ហើយក៏ជាគោលដៅដែលយើងទាំងអស់គ្នាខិតខំប្រឹងប្រែងដើម្បីសម្រេចបាន ។ ក្រោយពីប្រទេសចិនថ្មីត្រូវបានបង្កើតឡើងរៀងមកជនជាតិទួឡុង បានលាចាកពីការរស់នៅដែលមានស្ថានភាពដូចសម័យបុរាណ ។ ក្រោយពីចូលក្នុងយុគសម័យថ្មីជនជាតិទួឡុងបានកាត់បន្ថយនូវភាពក្រីក្រទាំងស្រុង ។ នេះបានសបញ្ជាក់ឱ្យឃើញថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវពីគណបក្សកុម្មុយនិស្តចិន ព្រមទាំងការរួមសាមគ្គីគ្នានិងកិច្ចខិតខំប្រឹងប្រែងរបស់មហាជនសុបិននៃការស្វែងរកជីវភាពសុភមង្គលរបស់ប្រជាជនមុខជានឹងអាចត្រូវបានសម្រេចជាមិនខាន ។

ឯកឧត្តម បានលើកទឹកចិត្តប្រជាជនថា ការកាត់បន្ថយភាពក្រីក្រគ្រាន់តែជាជំហានទី១ ។ ការរស់នៅយ៉ាងល្អប្រសើរកំពុងរង់ចាំអ្នកទាំងអស់គ្នា ។ ឯកឧត្តមសង្ឃឹមថា បងប្អូនជនរួមជាតិទាំងអស់គ្នានឹងអាចខិតខំប្រឹងប្រែងបន្តទៀត រួមសាមគ្គីគ្នាជាធ្លុងមួយដើម្បីកសាងស្រុកកំណើតរបស់ខ្លួននិងការពារតំបន់ព្រំដែនឱ្យបានល្អប្រសើរ ព្រមទាំងកសាងអនាគតកាន់តែភ្លឺស្វាងរបស់ជនជាតិទួឡុង ។

ជនជាតិទួឡុង ជាជនជាតិមួយក្នុងចំណោមជនជាតិភាគតិចដែលមានប្រជាជនចំនួនតិចទាំង២៨ នៅប្រទេសចិន ហើយក៏ជាជនជាតិមួយដែលបានវិវត្តពីសង្គមសម័យដើមចូលក្នុងសម័យសង្គមនិយមដោយផ្ទាល់ ក្រោយពីប្រទេសចិនថ្មីត្រូវបានបង្កើតឡើង ។

នៅចុងឆ្នាំ២០១៨ ប្រជាជនជនជាតិទួឡុង បានសម្រេចនូវការកាត់បន្ថយភាពក្រីក្រទាំងស្រុងដែលបានធ្វើឱ្យអត្រានៃភាពក្រីក្រធ្លាក់ចុះដល់កម្រិត ២,៦ភាគរយ ។ ប្រជាជន ១០៨៦ គ្រួសារនៅឃុំទន្លេទួឡុងបានចូលស្នាក់នៅក្នុងផ្ទះថ្មីទាំងអស់គ្នា ហើយបានសាងសង់ផ្លូវដីរឹងនៅគ្រប់ភូមិនិងមានសេវាបណ្តាញ 4G សេវាទូរទស្សន៍និងវិទ្យុផ្សាយសំឡេងគ្របដណ្តប់លើគ្រប់តំបន់ក្នុងឃុំនេះ ។ ប្រជាជនជនជាតិទួឡុងប្រកបរបរដាំផ្លែឈើចិញ្ចឹមសត្វឃ្មុំ និងគោ ហើយអាចទទួលបានឆ្វរំចំណូលកាន់តែច្រើនឡើងៗ ។ កុមារាកុមារីអាចទទួលការអប់រំដោយឥតគិតថ្លៃចំណែកប្រជាជនក៏អាចទទួលសេវាកម្មសុខាភិបាលដែលមានលក្ខណៈកាន់តែល្អប្រសើរដែរ ៕

● តាមពិតមានមនុស្សច្រើនមិនសូវស្គាល់ជនជាតិទួឡុងទេ

ជនជាតិទួឡុង ជាជនជាតិភាគតិចមួយដែលរស់នៅក្នុងតំបន់ដាច់ស្រយាល ។ ប៉ុន្តែ ឯកឧត្តម ស៊ី ជីនភីង បានបញ្ជាក់ថា "ខ្ញុំស្គាល់ជនជាតិទួឡុងនេះ ពីព្រោះខ្ញុំនិងប្រជាជនជនជាតិទួឡុងធ្លាប់សរសេរសំបុត្រទាក់ទងគ្នា ។ មុននឹងបុណ្យចូលឆ្នាំសាកល ២០១៤ មហាជន និងកម្មាភិបាលនៅស្រុកស្វយ័តជនជាតិទួឡុង និងជនជាតិន្ទកុងសាន បានសរសេរសំបុត្រជូនឯកឧត្តមប្រធានាធិបតី ស៊ី ជីនភីង ដើម្បីរាយការណ៍អំពីការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច ព្រមទាំងការកែលម្អជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់នោះ ។ ពួកគេបានសរសេរក្នុងសំបុត្រនេះថា ផ្លូវឆ្លងភ្នំកុងសាននៅឃុំទន្លេទួឡុងនឹងត្រូវដាក់ឱ្យប្រើប្រាស់ក្នុងពេលឆាប់ៗ ។ ក្រោយពីទទួលដំណឹងនេះ ឯកឧត្តម ស៊ី ជីនភីង បានសរសេរសំបុត្រតបអ្នកស្រុកភ្លាមៗថា ខ្ញុំសូមអបអរសាទរប្រជាជនជនជាតិទួឡុង! ឯកឧត្តមសង្ឃឹមថាប្រជាជនជនជាតិទួឡុងនឹងពន្លឿនដំណើរនៃការកាត់បន្ថយភាពក្រីក្រនិងសម្រេចបាននូវក្តីបំណងដ៏ល្អបវរអំពីជីវភាពធូរធារដោយរួមគ្នាជាមួយបងប្អូនគ្រប់ជនជាតិក្នុងប្រទេសចិន ។

នៅខែមករា ឆ្នាំ ២០១៥ ឯកឧត្តម ស៊ី ជីនភីង បានអញ្ជើញទៅបំពេញទស្សនកិច្ចនៅខេត្តយូនណាន។ ឯកឧត្តម បានយកចិត្តទុកដាក់ដល់ការសាងសង់ផ្លូវឆ្លងភ្នំកុងសាននិងការរីកចម្រើននៃជីវភាពរស់នៅរបស់ជនជាតិទួឡុង ។ ក្នុងដំណើរទស្សនកិច្ចនេះ ឯកឧត្តមបានអញ្ជើញឱ្យមហាជន និង កម្មាភិបាលដែលធ្លាប់សរសេរសំបុត្រ ជូនឯកឧត្តមធ្វើដំណើរមកដល់ក្រុង គុនមីង ហើយឆ្លៀតពេលដ៏ជាប់រវល់ដើម្បី ជួបសំណេះសំណាលជាមួយពួកគេ ៕

រដ្ឋមន្ត្រីការបរទេសចិន៖ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិន ជាកិច្ចប្រជុំដ៏សំខាន់

ក្នុងរយៈពេលពីរថ្ងៃនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិន ដែលធ្វើឡើងនៅទីក្រុងសិង្ហបុរី រដ្ឋមន្ត្រីការបរទេសចិន លោក វ៉ាង យី បានជួបពិភាក្សាទ្វេភាគីជាមួយនឹងរដ្ឋមន្ត្រីការបរទេសនៃប្រទេសជាសមាជិកអាស៊ាន ដើម្បីពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។

លោក វ៉ាង យី បានលើកឡើងថា ក្នុងនាមជាប្រទេសជិតខាងដែលមានទឹកដីជាប់គ្នា ចិននិងអាស៊ានមានទំនាក់ទំនងដែលមិនអាចកាត់ផ្តាច់បាន ហើយមានការអភិវឌ្ឍយ៉ាងលឿនក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក។ ក្នុងនាមជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ចិននិងអាស៊ានមានមូលដ្ឋានរឹងមាំក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ ដោយសារតែមានការយល់ដឹងគ្នាយ៉ាងជ្រាលជ្រៅ ការជឿទុកចិត្តគ្នាយ៉ាងរឹងមាំ និងការគាំទ្រគ្នាទៅវិញទៅមក។

លោក វ៉ាង យី បានលើកឡើងថា ចិនសង្ឃឹមថា តាមរយៈកិច្ចប្រជុំនេះ ភាគីនានានឹងអាចផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកឱ្យបានកាន់តែស៊ីជម្រៅថែមទៀត រួមគ្នាពិគ្រោះពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ។ ដូចប្រសាសន៍របស់ឯកឧត្តម ស៊ី ជីនភីង ថា គំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" មានប្រភពពីប្រទេសចិនតែ ជាជោគជ័យរបស់ពិភពលោក ។ យើងសង្ឃឹមហើយជឿជាក់ថា វេទិកាកំពូល ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ "ខ្សែក្រវាត់មួយ និងផ្លូវមួយ" លើកទី២ មុខជានឹងអាចទទួលបានជោគជ័យយ៉ាងគាប់ប្រសើរ និងក្លាយទៅជានិមិត្តសញ្ញាថ្មីមួយក្នុងដំណើរនៃការកសាង "ខ្សែ ក្រវាត់មួយ និងផ្លូវមួយ"៕ **(ក្រសួងការបរទេសចិន)**

វេទិកាកំពូលស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ "ខ្សែក្រវាត់មួយ និងផ្លូវមួយ" លើកទី២សម្ពោធនៅខែមេសា

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ ២០១៩ ឯកឧត្តម វ៉ាង យី សមាជិកក្រុមប្រឹក្សាកិច្ចការរដ្ឋចិននិងជារដ្ឋមន្ត្រីក្រសួងការបរទេសចិនបានប្រកាសជាសាធារណៈក្នុងសន្និសីទសារព័ត៌មានអំពីកិច្ចប្រជុំសភាតំណាងប្រជាជន និងសភាប្រឹក្សានយោបាយប្រជាជនថា វេទិកាកំពូលស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ"ខ្សែក្រវាត់មួយនិងផ្លូវមួយ" លើកទី២ នឹងរៀបចំនៅចុងខែមេសា ក្នុងទីក្រុងប៉េកាំង ។ វេទិកាកំពូលនេះ គឺជាព្រឹត្តិការណ៍ការទូតសំខាន់ជាងគេដែលប្រទេសចិនធ្វើជាម្ចាស់ផ្ទះរៀបចំនៅឆ្នាំនេះ ហើយក៏ជាកិច្ចប្រជុំអន្តរជាតិដ៏សំខាន់មួយទៀតដែលអាចទទួលបាននូវការចាប់អារម្មណ៍ពីពិភពលោកទាំងមូលដែរ ។ ឯកឧត្តម ស៊ី ជីនភីង នឹងអញ្ជើញចូលរួមនិងថ្លែងសុន្ទរកថាសំខាន់ក្នុងពិធីបើកសម្ពោធវេទិកាកំពូលនេះ ហើយនឹងចូលរួមជាអធិបតី ក្នុងកិច្ចប្រជុំតុមូលថ្នាក់ដឹកនាំកំពូល ។ ក្រៅពីនេះ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់វេទិកាពាក់ព័ន្ធផ្សេងៗទៀត និងកម្មវិធី ឧស្សាហកម្ម និងពាណិជ្ជកម្មមួយចំនួនធំនឹងត្រូវរៀបចំឡើងក្នុងឱកាសវេទិកាកំពូលនេះ។

ឯកឧត្តម វ៉ាង យី បានមានប្រសាសន៍ថា វេទិកាកំពូលលើកទី ២ នេះ មានលក្ខណៈពិសេសសំខាន់ចំនួន ៣ គឺ ទី១-មានកម្រិតកាន់តែខ្ពស់ ពោលគឺនឹងមានប្រមុខរដ្ឋនិងរដ្ឋាភិបាលនៃប្រទេសផ្សេងៗច្រើនជាងវេទិកាកំពូលលើកទី១ ។ ទី២-មានទ្រង់ទ្រាយកាន់តែធំ ពោលគឺនឹងមានតំណាងរាប់ពាន់នាក់ ដែលមកពីប្រទេសចំនួនជាង១០០ មកចូលរួមក្នុងវេទិកាកំពូលនេះ ។ ទី៣-មានសកម្មភាពកាន់តែច្រើន ពោលគឺនឹងរៀបចំវេទិកាពាក់ព័ន្ធចំនួន១២ សម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការជាក់ស្តែង ។ ជាពិសេសមហាសន្និបាតសហគ្រិនលើកទី១ នឹងត្រូវរៀបចំក្នុងឱកាសវេទិកាកំពូលនេះដើម្បីបង្កើតវេទិកាសំខាន់សម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម ។

ឯកឧត្តម វ៉ាង យី បានថ្លែងថា វេទិកាកំពូលនេះនឹងរៀបចំក្រោមប្រធានបទ"រួមគ្នាស្តាបនាខ្សែក្រវាត់ និងផ្លូវកសាងអនាគតកាន់តែភ្លឺស្វាង "ហើយនឹងផ្តល់អាទិភាពដល់ការជំរុញកិច្ចសហប្រតិបត្តិការ"ខ្សែក្រវាត់មួយ និងផ្លូវមួយ"ដោយមានគុណភាពខ្ពស់។ យើងសង្ឃឹមថា ភាគីនានានឹងអាចផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកឱ្យបានកាន់តែស៊ីជម្រៅថែមទៀតរួមគ្នាពិគ្រោះពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ។ដូចប្រសាសន៍របស់ឯកឧត្តម ស៊ី ជីនភីង ថា គំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" មានប្រភពពីប្រទេសចិនតែ ជាជោគជ័យរបស់ពិភពលោក ។ យើងសង្ឃឹមហើយជឿជាក់ថា វេទិកាកំពូល ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ "ខ្សែក្រវាត់មួយ និងផ្លូវមួយ" លើកទី២មុខជានឹងអាចទទួលបានជោគជ័យយ៉ាងគាប់ប្រសើរ និងក្លាយទៅជានិមិត្តសញ្ញាថ្មីមួយក្នុងដំណើរនៃការកសាង "ខ្សែ ក្រវាត់មួយ និងផ្លូវមួយ"៕ **(ក្រសួងការបរទេសចិន)**

ដំណើរចម្រុះពណ៌នៃមណ្ឌលឌីឈីងខេត្តយូណាន

ទេសភាពដ៏ទាក់ទាញ ក្នុងទិវាគយគន់សត្វស្លាបរដូវរងា សាំងគ្រីឡា

ពេលថ្មីៗនេះ សន្និសីទសារព័ត៌មានអំពីបដិវត្តន៍ទេសចរណ៍"សាំងគ្រីឡា របស់ពិភពលោក" និងការប្រកាសផលិតផលទេសចរណ៍ឌីឈីងនៃកម្មវិធី" ដើរលេងខេត្តយូនណាន ដោយប្រើទូរស័ព្ទតែមួយគ្រឿង" បានត្រូវរៀបចំនៅក្រុងគុនមីង នៃខេត្តយូនណាន ។ ក្នុងសន្និសីទសារព័ត៌មាននេះរដ្ឋបាលខេត្តយូនណាន បានធ្វើបទបង្ហាញអំពីការអនុវត្តបដិវត្តន៍ទេសចរណ៍និងគម្រោងវិស្វកម្មសំខាន់ចំនួន ៩ អំពីបដិវត្តន៍ទេសចរណ៍មណ្ឌលឌីឈីង ឆ្នាំ២០១៩ ។ មិនតែប៉ុណ្ណោះ ទេផលិតផលទេសចរណ៍ជាគំរូរបស់មណ្ឌលស្វយ័តជនជាតិទីបេត៍ឌីឈីង ក្នុងកម្មវិធី" ដើរលេងខេត្តយូនណាន ដោយប្រើទូរស័ព្ទតែមួយគ្រឿង" បានត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងឱកាសនេះរួមមានពិធីបុណ្យចំនួន ៥ ដំណើរទេសចរណ៍ពិសេសចំនួន ៦ ផ្លូវទេសចរណ៍បរទ្បានខ្លួនឯងចំនួន ៧ ផ្លូវទេសចរណ៍មនុស្សដើរចំនួន៨ និងតំបន់គំរូទេសចរណ៍ជនបទចំនួន ៩ ជាដើម ។

ពិធីបុណ្យចំនួន ៥ រួមមានទិវាតន្ត្រីបាក្រាជុង និងទិវាប្រកួតសេះសាំងគ្រីឡាជាដើម។ ដំណើរទេសចរពិសេសចំនួន៦ រួមមានដំណើរទេសចរផ្កាតារៅ ដំណើរទេសចរផ្សិតសុងយ៉ុង និងដំណើរទេសចរមើលសត្វស្លាបជាដើម។ផ្លូវទេសចរណ៍បរទ្បានខ្លួនឯងចំនួន ៧ រួមមានខ្សែផ្លូវទេសចរណ៍គុនមីង-តាលី-លីជាំង-សាំងគ្រីឡា-យ៉ានជីង-ឡាសាជាដើម។ ផ្លូវទេសចរណ៍មនុស្សដើរចំនួន៨ រួមមានខ្សែផ្លូវទេសចរណ៍មនុស្សដើរភ្នំព្រិលម៉ីលី-ភូមិយូពីងជាដើម។តំបន់គំរូទេសចរណ៍ជនបទចំនួន៩រួមមានភូមិយូពីងជាដើម។

នាពេលខាងមុខ រដ្ឋបាលមណ្ឌលឌីឈីង នឹងខិតខំជំរុញដោយគ្រប់ជ្រុងជ្រោយនូវការអនុវត្តវិស្វកម្មសំខាន់ទាំង៩ នៃ"បដិវត្តន៍ទេសចរណ៍" មណ្ឌលឌីឈីង តាមរយៈការកសាងទីដៅទេសចរណ៍ពេញលក្ខណៈជំរុញការកែទម្រង់ផលិតផលទេសចរណ៍ សាងសង់ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ លើកកម្ពស់សេវាកម្មនិងការគ្រប់គ្រងទេសចរណ៍និងការបង្កើតប្រព័ន្ធទេសចរណ៍វៃឆ្លាត ដើម្បីជំរុញឱ្យមណ្ឌលឌីឈីង ក្លាយទៅជាតំបន់គំរូនៃការកែទម្រង់និងការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍នៃខេត្តយូណាន ៕

ស៊ីសាំងប៉ានណា៖ មនុស្សរាប់ម៉ឺននាក់រួមគ្នាអបអរបុណ្យបាចទឹក

នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០១៩ពិធី អបអរសាទរបុណ្យបាចទឹកឆ្នាំ ២០១៩បានត្រូវរៀបចំនៅមណ្ឌលស្វយ័តជនជាតិតៃស៊ីសាំងប៉ានណា ខេត្តយូនណាន។ នៅរមណីយដ្ឋានកៅជួងស៊ីស្នងជឹងអ្នកស្រុកក្នុង តំបន់ និងទេសចររាប់ម៉ឺននាក់បានជួបជុំគ្នាយ៉ាងសប្បាយរីករាយហើយបានបាចទឹកគ្នា ទៅវិញទៅមកដើម្បីអបអរសាទរបុណ្យចូលឆ្នាំ ថ្មីជនជាតិតៃ និងជូនពរឱ្យមានសិរីមង្គលនិងសុខភាពល្អបរិបូណ៌គ្រប់ៗគ្នា ៕ **ដោយលី ម៉ង**